# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ...១៦.....អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ

*******

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០០/០០១ ចុះថ្ងៃទី ២១ខែមិថុនា ឆ្នាំ២០០០ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាពលើផលិតផលទំនិញ និងសេវា
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី ១៤ ខែកុម្ភៈ ឆ្នាំ ២០០៣

# សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះមានគោលបំណងកំណត់ការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ ដើម្បីទប់ស្កាត់ការរីករាលដាលឆ្លងជំងឺសត្វ ការពារសុខភាពសត្វ និងការពារសុខភាពសាធារណៈ ដោយអនុវត្តវិធានបសុពេទ្យ លើរាល់ការនាំចូល នាំចេញ ឆ្លងកាត់ និងដឹកជញ្ជូនទំនិញដែលជាកម្មវត្ថុនៃការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ ពីតំបន់មួយទៅតំបន់មួយទៀត ក្នុងព្រះរាជាណាចក្រកម្ពុជា តាមគ្រប់មធ្យោបាយចម្លងជំងឺពីសត្វ ឬផលិតផលមានដើមកំណើតពីសត្វទៅសត្វ ឬពីសត្វទៅមនុស្ស ឬពីមនុស្ស ទៅសត្វ ។

**មាត្រា ២.-**

រាល់ការនាំយក ឬដឹកជញ្ជូនទំនិញដែលជាកម្មវត្ថុ នៃការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វនាំចូល នាំចេញ ឆ្លងកាត់ ឬដឹកជញ្ជូនទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ ក្នុងព្រះរាជាណាចក្រកម្ពុជា ម្ចាស់ទំនិញនោះត្រូវសុំការត្រួតពិនិត្យ និងត្រូវគោរព តាមគ្រប់វិធានបសុពេទ្យ ។

**មាត្រា ៣.-**

រដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទមានភារកិច្ចទទួលខុសត្រូវ លើការអនុវត្តការងារត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ ដោយមានសមត្ថកិច្ចត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ នៃនាយកដ្ឋានផលិតកម្ម និងបសុព្យាបាលជាអ្នកអនុវត្តផ្ទាល់ ។

**មាត្រា ៤.-**

និយមន័យនៃពាក្យសំខាន់ៗដែលប្រើប្រាស់សម្រាប់អនុក្រឹត្យនេះមានដូចខាងក្រោម:

ក-**ការត្រួតពិនិត្យអនាម័យសត្វ និងផលិតមានដើមកំណើតពីសត្វ:** សំដៅ

ដល់ការពិនិត្យស្រាវជ្រាវរកមេរោគបង្កជំងឺ ឬជាតិពុលបណ្តាលមកពីអតិសុខុមប្រាណ ដើម្បីការពារសុខភាពសត្វ និងសុខភាពសាធារណៈ ។

ខ-**ការដឹកជញ្ជូនឆ្លងកាត់**: សំដៅដល់ការដឹកជញ្ជូនទំនិញ ដែលជាកម្មវត្ថុនៃការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វឆ្លងកាត់ទឹកដី នៃព្រះរាជាណាចក្រកម្ពុជា ។ ការដឹកជញ្ជូនឆ្លងកាត់នេះ មិនរាប់បញ្ចូលការរើទំនិញ ការឈប់ដើម្បីដាក់ទំនិញចូលឃ្លាំង ការបើកសម្ភារៈវេចខ្ចប់ទំនិញ ឬផ្លាស់ប្តូរមធ្យោបាយដឹកជញ្ជូនឡើយ ។

គ-**ការទប់មេរោគ** : សំដៅដល់វិធានការកម្ចាត់មេរោគ ភ្នាក់ងារបង្កជំងឺសត្វ ឬពពួកប៉ារ៉ាស៊ីត បង្កជំងឺសត្វតាមរយៈការចម្លងផ្ទាល់ ឬមិនផ្ទាល់ ។

ឃ-**ទំនិញ** : សំដៅដល់សត្វគ្រប់ប្រភេទ ផលិតផលមានដើមកំណើតពីសត្វ និងចំណីសត្វដែលបានធ្វើចលនា ឬចរាចរដើម្បីលក់ដូរ ឬបំណងផ្សេងទៀត ។

ង-**ផលិតផលមានដើមកំណើតពីសត្វ**: សំដៅដល់ :

១-សត្វស្លាប់ ឬសត្វដែលបានសម្លាប់ ឬផ្នែកណាមួយរបស់សត្វ ដែលមិនទាន់ត្រូវបានយកទៅចម្អិន ឬសម្រាប់យកទៅធ្វើការកែច្នៃជាផលិតផលផ្សេងៗ ។

២-ភ្លុក ស្នែង និងរោមដែលបានកាត់ចេញពីសត្វរស់ ឬសត្វស្លាប់ ដែលមិនទាន់យកទៅកែច្នៃ ។

៣- សាច់សត្វឬផលិតផលទាំងឡាយណា ដែលមានដើមកំណើតពីសត្វសម្រាប់ផ្គត់ផ្គង់ម្ហូបអាហារមនុស្ស ចំណីសត្វ និងប្រើប្រាស់ក្នុងផ្នែកសុខាភិបាល ផ្នែកកសិកម្ម ឬផ្នែកឧស្សាហកម្ម ។

ច-**ភ្នាក់ងារបសុពេទ្យ**: សំដៅដល់មន្ត្រីបសុពេទ្យ ដែលប្រតិបត្តិការក្នុងការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វគ្រប់កន្លែង ឬយកវត្ថុវិភាគពីសត្វ ឬផលិតផលមានដើមកំណើតពីសត្វ ដើម្បីធ្វើការវិភាគ ។

ឆ-**មធ្យោបាយចម្លងជំងឺសត្វ** : សំដៅដល់សត្វគ្រប់ប្រភេទ ផលិតផលមានដើមកំណើតពីសត្វ ចំណីសត្វ មនុស្ស មធ្យោបាយដឹកជញ្ជូន ឧបករណ៍ចិញ្ចឹម ឧបករណ៍ដាក់សត្វ ឬសម្ភារៈវេចខ្ចប់ដែលបង្កឱ្យមានអតិសុខុមប្រាណ និងបង្កឱ្យមានជំងឺឆ្លងរាតត្បាតសត្វ ។

ហ

ជ-**មេរោគបង្កជំងឺសត្វ**: សំដៅដល់វីរុស បាក់តេរី ប៉ារ៉ាស៊ីត ផ្សិត និងប្រភេទអតិសុខុមប្រាណផ្សេងទៀត ។

ឈ-**មធ្យោបាយដឹកជញ្ជូន**: សំដៅដល់ឧបករណ៍ដាក់ទំនិញ ដែលជាកម្មវត្ថុនៃការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ ដើម្បីធ្វើចរាចរ ។

ញ-**វិធានបសុពេទ្យ** : សំដៅដល់ការបំបែក បញ្ចេញចោល រំងាប់មេរោគ ធ្វើអនាម័យ កាត់ផ្តាច់មិនឱ្យឆ្លងបាន ឃាត់ទុក ចាក់ថ្នាំការពារ ព្យាបាល បង្វែរទិសដៅប្រើប្រាស់ទំនិញ បញ្ជូនត្រឡប់ទៅប្រភពដើមវិញ សម្លាប់ចោល កប់ចោល ឬដុតបំផ្លាញចោល ទំនិញដែលជាកម្មវត្ថុនៃការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ ។

ដ-**វិញ្ញាបនបត្រអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ** : សំដៅដល់វិញ្ញាបនបត្រ ដែលចេញដោយសមត្ថកិច្ចផលិតកម្ម និងបសុព្យាបាល បន្ទាប់ពីបានធ្វើការត្រួតពិនិត្យ ឬវិភាគទំនិញដែលជាកម្មវត្ថុ នៃការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ ឃើញថាមានសុខភាពល្អ និងគ្មានមេរោគបង្កជំងឺឆ្លងតាមលក្ខណបច្ចេកទេសបសុពេទ្យ ។

ឋ-**សត្វ** :សំដៅដល់ :

១-សត្វចតុប្បាទស្រុក និងព្រៃ រួមទាំងអម្បូរសម្រាប់បង្កាត់ពូជទាំងនោះ

២-សត្វស្លាបស្រុក និងព្រៃ រួមទាំងអម្បូរសម្រាប់បង្កាត់ពូជទាំងនោះ

៣-ស្វា ទោច រួមទាំងអម្បូរសម្រាប់បង្កាត់ពូជទាំងនោះ

៤-ឃ្មុំ ដង្កូវនាង ឧរង្គសត្វ មណ្ឌុកសត្វ សិប្បីជាតិ សត្តវង្គជាតិ មច្ឆជាតិ

៥-ស៊ុតសម្រាប់ភ្ញាស់ ទឹកកាមសត្វ អំប្រីយ៉ុងសត្វ

ឌ- **ស្ថានីយចត្តាឡីស័កសត្វ** : សំដៅដល់កន្លែងបង្ខាំងសត្វ ឬបំបែកសត្វទុកដោយឡែកដើម្បីធ្វើការសង្កេតត្រួតពិនិត្យជំងឺរាតត្បាតសត្វ និងមានវិធានបសុពេទ្យ តាមពេលវេលាកំណត់ដោយស្ថិតនៅក្រោមការគ្រប់គ្រងរបស់ភ្នាក់ងារបសុពេទ្យ តាមលក្ខណបច្ចេកទេស ។

ឍ-**សម្ភារៈវេចខ្ចប់** : សំដៅដល់សម្ភារៈរុំ ឬវេចខ្ចប់បំណែកណាមួយនៃសត្វ ឬផលិតផលមានដើមកំណើតពីសត្វឱ្យមានអនាម័យ និងសុវត្ថិភាព ។

ណ-**ឧបករណ៍ដាក់សត្វ** : សំដៅដល់សម្ភារៈសម្រាប់ដាក់សត្វឱ្យមានសុវត្ថិភាព ក្នុងពេលដឹកជញ្ជូន ។

## ជំពូកទី ២

## ការត្រួតពិនិត្យអនាម័យសត្វ

## និងផលិតផលមានដើមកំណើតពីសត្វ

**មាត្រា ៥.-**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវចាត់បញ្ជូនមន្ត្រីត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ និងមន្ត្រីភូតគាមអនាម័យ ទៅចូលរួមបំពេញភារកិច្ចតាមសមត្ថកិច្ចរៀងៗខ្លួននៅតាមទីស្នាក់ការត្រួតពិនិត្យច្រកទ្វារអន្តរជាតិ ច្រកទ្វារព្រំដែនអន្តរជាតិ ច្រកទ្វារព្រំដែនទ្វេភាគី ច្រកទ្វារតំបន់ព្រំដែន និងច្រកទ្វារកំពង់ផែសមុទ្រ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា តាមការកំណត់របស់រាជរដ្ឋាភិបាល ដោយអនុក្រឹត្យ ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាចបង្កើតទីស្នាក់ការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ រួមគ្នាជាមួយទីស្នាក់ការត្រួតពិនិត្យភូតគាមអនាម័យ នៅតាមស្ថានីយ៍រថភ្លើង ផែស្ងួត កំពង់ផែ និង អាកាសយានដ្ឋានក្នុងស្រុក តាមការអនុញ្ញាតរបស់រាជរដ្ឋាភិបាល ។

ក្នុងករណីចាំបាច់ ពេលមានប្រភពមេរោគបង្កជំងឺឆ្លងសត្វ ឬជំងឺឆ្លងរាតត្បាតសត្វ ឬមានភាពអនាធិបតេយ្យចលនាសត្វ និងផលិតផលមានដើមកំណើតពីសត្វ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទអាចប្រកាសបង្កើតស្នាក់ការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វជាបណ្តោះអាសន្នជាបន្ទាន់ នៅតាមទីតាំងចាំបាច់ ដើម្បីទប់ស្កាត់ការរីករាលដាលជំងឺឆ្លងសត្វ ឬភាពអនាធិបតេយ្យចលនាសត្វ និងផលិតផលមានដើមកំណើតពីសត្វ ។ នៅពេលបញ្ហាខាងលើត្រូវបានបំបាត់ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវចេញប្រកាសរំសាយស្នាក់ការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វទាំងនោះ ។

ទីស្នាក់ការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ ត្រូវបំពាក់ដោយ

u

សម្ភារៈឧបករណ៍បច្ចេកទេសសមស្រប ដើម្បីធានាបាននូវប្រសិទ្ធភាព នៃការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ ។

ទីស្នាក់ការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់ របស់នាយកដ្ឋានផលិតកម្ម និងបសុព្យាបាលនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ៦.-**

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវបង្កើតស្ថានីយ៍ចត្តាឡីស័កសត្វ នៅតាមទីស្នាក់ការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ ដែលបានការអនុញ្ញាតពីរាជរដ្ឋាភិបាលឱ្យដាក់ ។

**មាត្រា ៧.-**

ការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ ត្រូវអនុវត្តតាមលក្ខខណ្ឌអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វនៃប្រទេសនីមួយៗ ។

**មាត្រា ៨.-**

ទំនិញដែលជាកម្មវត្ថុនៃការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វមាន :

១- សត្វគ្រប់ប្រភេទ

២- ផលិតផលមានដើមកំណើតពីសត្វ និងចំណីសត្វ

៣- មធ្យោបាយដឹកជញ្ជូន ឧបករណ៍ចិញ្ចឹម ឧបករណ៍ដាក់សត្វ និងសម្ភារៈវេចខ្ចប់ផលិតផលមានដើមកំណើតពីសត្វ ។

បញ្ជីមុខទំនិញដែលជាកម្មវត្ថុនៃការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ ត្រូវកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និងថាមពល និងរដ្ឋមន្ត្រីក្រសួង សុខាភិបាល ។

**មាត្រា ៩.-**

ម្ចាស់ទំនិញដែលជាកម្មវត្ថុនៃការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ ត្រូវអនុវត្តតាមនីតិវិធី ដូចខាងក្រោម :

- ធ្វើប្រតិវេទន៍ទំនិញឱ្យបានត្រឹមត្រូវ

- មានវិញ្ញាបនបត្រអនាម័យ
- បង្ហាញលិខិតដឹកនាំទំនិញដល់មន្ត្រីត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ
- ធានាគុណភាព សុវត្ថិភាព និងអនាម័យនៃមធ្យោបាយដឹកជញ្ជូន ឧបករណ៍ចិញ្ចឹម ឧបករណ៍ដាក់សត្វ សម្ភារៈវេចខ្ចប់ផលិតផលមានដើមកំណើតពីសត្វ
- ដឹកជញ្ជូន ឬដាក់ទំនិញតាមកន្លែង ដែលមន្ត្រីត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វបានកំណត់ ដោយសហការជាមួយសមត្ថកិច្ចពាក់ព័ន្ធ
- បង្កភាពងាយស្រួលដល់មន្ត្រីត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វក្នុងការកាត់សំណាកទំនិញដើម្បីធ្វើវិភាគ
- សុំការអនុញ្ញាតជាមុនពីសមត្ថកិច្ចត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វក្នុងករណីដឹកជញ្ជូន ឬដាក់ទំនិញក្រៅពីការកំណត់ ដោយសហការណ៍ជាមួយសមត្ថកិច្ចពាក់ព័ន្ធ ។

**មាត្រា ១០.-**

មុនការនាំទំនិញ ចេញ ចូល ម្ចាស់ទំនិញត្រូវដាក់ពាក្យសុំត្រួតពិនិត្យ មកសមត្ថកិច្ចត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ ។

មុនពេលទំនិញចូលមកដល់ច្រកទ្វារព្រំដែន ម្ចាស់ទំនិញត្រូវជូនដំណឹងទៅទីស្នាក់ការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ ហើយត្រូវបង្កលក្ខណៈងាយស្រួលដល់ការត្រួតពិនិត្យ ។

**មាត្រា ១១.-**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលបានស្នើសុំធ្វើការត្រួតពិនិត្យអនាម័យសត្វ ឬផលិតផលមានដើមកំណើតពីសត្វ លើទំនិញរបស់ខ្លួន ត្រូវបង់សោហ៊ុយសេវាកម្មត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ ។ សោហ៊ុយសេវាកម្មនេះ ត្រូវបង់ចូលថវិកាជាតិ ។ សោហ៊ុយសេវាកម្មត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ ត្រូវកំណត់ដោយប្រកាសរួម របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ១២.-**

រូបវន្តបុគ្គល ឬនីតិបុគ្គលអាចផ្តល់ព័ត៌មានដល់សមត្ថកិច្ចត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើម

កំណើតពីសត្វ ដែលនៅជិតបំផុត ក្នុងករណីដែលបានឃើញ ៖

ក- កប៉ាល់ កាណូត ទូក ឬមធ្យោបាយដឹកជញ្ជូនផ្សេងៗទៀត ដែលមានទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ លេចធ្លាយ ឬខូចគ្រឿងចក្ររសាត់អណ្តែត ឬបើកឆ្លងចូលមកដែនទឹកនៃព្រះរាជាណាចក្រកម្ពុជា ។

ខ- ទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ ដែលយន្តហោះបានទម្លាក់មកលើទឹកដី នៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ១៣.-**

ក្នុងពេលប្រតិបត្តិការ សមត្ថកិច្ចត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ ត្រូវស្លៀកពាក់ឯកសណ្ឋាន ពាក់សញ្ញាសម្គាល់ និងមានលិខិតបញ្ជាបេសកកម្មជាប់នឹងខ្លួន ។

ឯកសណ្ឋាន សញ្ញាសម្គាល់របស់មន្ត្រីត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ ត្រូវកំណត់ដោយអនុក្រឹត្យមួយដោយឡែក ។

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវចេញប្រកាសស្តីពីនីតិវិធីនៃការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ ព្រមទាំងប្រកាស ឬសារាចរណែនាំដទៃទៀត ដើម្បីឱ្យដំណើរការនៃការអនុវត្តអនុក្រឹត្យនេះ ប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគ្មានភាពរើសអើងនៅក្នុងទូទាំងព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី ៣
## ការត្រួតពិនិត្យអនាម័យសត្វ
## និងផលិតផលមានដើមកំណើតពីសត្វក្នុងស្រុក

**មាត្រា ១៤.-**

ពេលមានប្រភពមេរោគបង្កជំងឺឆ្លង ឬជំងឺឆ្លងរាតត្បាតនៅតំបន់ណាមួយ ក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជា រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវប្រកាសនូវតំបន់ជំងឺឆ្លងរាតត្បាតសត្វ និងត្រូវ

មានវិធានបសុពេទ្យជាបន្ទាន់ ។

ការទិញ លក់ ឬការដឹកជញ្ជូនសត្វ និងផលិតផលមានដើមកំណើតពីសត្វ ចូល ចេញ ឬឆ្លងកាត់តំបន់នោះ ត្រូវផ្អាកជាបណ្តោះអាសន្ន រហូតដល់មានប្រកាសជាថ្មីរបស់រដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ១៥ .-**

សត្វឬផលិតផលមានដើមកំណើតពីសត្វ ឬមធ្យោបាយដឹកជញ្ជូន ត្រូវមានលក្ខណៈដូចខាងក្រោម :

ក-សត្វត្រូវមានសុខភាពល្អនាំមកពីតំបន់គ្មានជំងឺឆ្លង ឬមិនបានឆ្លងកាត់តំបន់មានជំងឺឆ្លងសត្វ និងត្រូវធ្វើការចាក់ថ្នាំការពារជំងឺយោងទៅតាមការកំណត់របស់សមត្ថកិច្ចផលិតកម្មនិងបសុព្យាបាល ។

ខ-ផលិតផលមានដើមកំណើតពីសត្វនិងចំណីសត្វ ត្រូវវេចខ្ចប់ឱ្យបានត្រឹមត្រូវតាមលក្ខណបច្ចេក-ទេស និងមានអនាម័យល្អ ។

គ-មធ្យោបាយដឹកជញ្ជូន ឧបករណ៍ចិញ្ចឹម ឧបករណ៍ដាក់សត្វ ឬសម្ភារៈវេចខ្ចប់ផលិតផលមានដើមកំណើតពីសត្វ ត្រូវរំងាប់មេរោគមុន និងក្រោយពេលដឹកជញ្ជូន ។

**មាត្រា ១៦.-**

បែបបទនៃការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វក្នុងស្រុក ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

## ជំពូកទី ៤

## ការត្រួតពិនិត្យអនាម័យសត្វ

## និងផលិតផលមានដើមកំណើតពីសត្វលើការនាំចូល និងការឆ្លងដែន

**មាត្រា ១៧.-**

បែបបទនៃការត្រួតពិនិត្យទំនិញនាំចូល ជាកម្មវត្ថុនៃការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ ត្រូវកំណត់ដូចតទៅ :

ℒ

- រូបវន្តបុគ្គល ឬនីតិបុគ្គលដែលនាំចូលសត្វ ផលិតផលមានដើមកំណើតពីសត្វ និងចំណីសត្វ ត្រូវជូនដំណឹងដល់សមត្ថកិច្ចត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វយ៉ាងតិច ប្រាំ(៥)ថ្ងៃមុនពេលដឹកទំនិញមកដល់ ។

- នៅពេលមកដល់ច្រកទ្វារព្រំដែននៃព្រះរាជាណាចក្រកម្ពុជា ម្ចាស់ទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ ត្រូវរាយការណ៍និងសុំការត្រួតពិនិត្យ ។ ទីស្នាក់ការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វត្រូវកំណត់ទីកន្លែងសមស្របតាមលក្ខណបច្ចេកទេស ដើម្បីធ្វើការត្រួតពិនិត្យ ។

ម្ចាស់ទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ ដែលដឹកជញ្ជូនតាមផ្លូវទឹក ពេលទំនិញចូលមកដល់ដែនទឹកនៃព្រះរាជាណាចក្រកម្ពុជា ត្រូវរាយការណ៍ជូនទីស្នាក់ការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ ដែលនៅជិតបំផុតដើម្បីសុំការត្រួតពិនិត្យ មធ្យោបាយដឹកជញ្ជូនទំនិញដែលជាកម្មវត្ថុនៃការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ អាចចូលចតនៅកំពង់ផែបាន លុះត្រាតែមានការអនុញ្ញាតពីទីស្នាក់ការត្រួតពិនិត្យ អនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ បន្ទាប់ពីការត្រួតពិនិត្យអនាម័យរួច ។

**មាត្រា ១៨.-**

ការត្រួតពិនិត្យលើការនាំចូលនូវទំនិញ ដែលជាកម្មវត្ថុនៃការត្រួតពិនិត្យអនាម័យសត្វនិងផលិតផលមានដើមកំណើតពីសត្វ ត្រូវអនុវត្តដោយផ្អែកលើបញ្ជីរាយឈ្មោះជំងឺឆ្លងរាតត្បាតសត្វ ។ ហាមនាំចូលសត្វ ឬផលិតផលមានដើមកំណើតពីសត្វ ដែលមានមេរោគបង្កជំងឺឆ្លងរាតត្បាត ដូចមានចែងក្នុងបញ្ជីរាយឈ្មោះជំងឺឆ្លងរាតត្បាតសត្វ ។

បញ្ជីរាយឈ្មោះជំងឺឆ្លងរាតត្បាតសត្វ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានសិទ្ធិកែប្រែបញ្ជីរាយឈ្មោះជំងឺឆ្លងរាតត្បាត សត្វនេះតាមការចាំបាច់ ។

ប្រកាសស្តីពីការកែប្រែបញ្ជីរាយឈ្មោះជំងឺឆ្លងរាតត្បាតសត្វនេះ នឹងចូលជាធរមានសាមសិប(៣០) ថ្ងៃបន្ទាប់ពីការផ្សព្វផ្សាយជាសាធារណៈ ។

៤៤

ក្នុងករណីចាំបាច់ និងបន្ទាន់ដែលបង្កគ្រោះថ្នាក់ទ្រង់ជំងឺឆ្លងនេះ ប្រកាសស្តីពីការកែប្រែបញ្ជីរាយឈ្មោះជំងឺឆ្លងរាតត្បាតសត្វ នឹងចូលជាធរមានត្រូវបន្ថយមកនៅត្រឹមម្ភៃបួន(២៤)ម៉ោង បន្ទាប់ពីបានផ្សព្វផ្សាយជាសាធារណៈ ។

**មាត្រា ១៩.-**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលដឹកជញ្ជូនសត្វ ឬផលិតផលមានដើមកំណើតពីសត្វ ចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តដូចតទៅ :

- មានវិញ្ញាបនបត្រអនាម័យដែលចេញដោយប្រទេសនាំទំនិញចេញ
- អនុវត្តតាមមាត្រា៩ លើកលែងតែវាក្យខណ្ឌទី៦ មាត្រា១០ និងមាត្រា១១ នៃអនុក្រឹត្យនេះ ។

**មាត្រា ២០.-**

សត្វ ឬផលិតផលមានដើមកំណើតពីសត្វ ដែលមិនសមស្របតាមលក្ខខណ្ឌដែលមានចែងក្នុងបទប្បញ្ញត្តិកិច្ចសន្យាពាណិជ្ជកម្ម កិច្ចព្រមព្រៀង អនុសញ្ញា និងលក្ខខណ្ឌដទៃទៀត របស់ព្រះរាជាណាចក្រកម្ពុជា សមត្ថកិច្ចត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ ត្រូវអនុវត្តនូវវិធានការដូចតទៅ :

- បញ្ជូនទំនិញត្រឡប់ទៅប្រទេសដើមវិញ
- បង្វែរទិសដៅប្រើប្រាស់ទំនិញ
- ដឹកជញ្ជូន និងដាក់ទំនិញតាមកន្លែងដែលសមត្ថកិច្ចត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វបានកំណត់
- បង្ខាំងសត្វនៅស្ថានីយ៍ចត្តាឡីស័កសត្វទុកសម្រាប់សង្កេតតាមដាន ធ្វើរោគវិនិច្ឆ័យ ទុកព្យាបាល ចាក់ថ្នាំការពារ ឬធ្វើការរំងាប់មេរោគ
- បំផ្លាញចោល ។

ក្នុងករណីបំផ្លាញចោលឬបញ្ជូនទំនិញត្រឡប់ទៅប្រទេសដើមវិញ ត្រូវចាត់វិធានការតាមច្បាប់ជាធរមាន ។

ក្នុងករណីទុកព្យាបាលចាក់ថ្នាំការពារ ធ្វើការរំងាប់មេរោគ ឃាត់ទុក ឬបំផ្លាញចោលម្ចាស់ទំនិញឬតំណាង ត្រូវទទួលបន្ទុកទាំងស្រុងលើការថែរក្សា ការចំណាយផ្សេងៗ និងសេវាកម្ម ។

ųr

ក្នុងករណីចាំបាច់ និងបន្ទាន់ដែលបង្កគ្រោះថ្នាក់នូវជំងឺឆ្លងនេះ ប្រកាសស្តីពីការកែប្រែបញ្ជីរាយឈ្មោះជំងឺឆ្លងរាតត្បាតសត្វ នឹងចូលជាធរមានត្រូវបន្ថយមកនៅត្រឹមម្ភៃបួន(២៤)ម៉ោង បន្ទាប់ពីបានផ្សព្វផ្សាយជាសាធារណៈ ។

**មាត្រា ១៩.-**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលដឹកជញ្ជូនសត្វ ឬផលិតផលមានដើមកំណើតពីសត្វ ចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តដូចតទៅ :

- មានវិញ្ញាបនបត្រអនាម័យដែលចេញដោយប្រទេសនាំទំនិញចេញ
- អនុវត្តតាមមាត្រា៩ លើកលែងតែវាក្យខណ្ឌទី៦ មាត្រា១០ និងមាត្រា១១ នៃអនុក្រឹត្យនេះ ។

**មាត្រា ២០.-**

សត្វ ឬផលិតផលមានដើមកំណើតពីសត្វ ដែលមិនសមស្របតាមលក្ខខណ្ឌដែលមានចែងក្នុងបទប្បញ្ញត្តិកិច្ចសន្យាពាណិជ្ជកម្ម កិច្ចព្រមព្រៀង អនុសញ្ញា និងលក្ខខណ្ឌដទៃទៀត របស់ព្រះរាជាណាចក្រកម្ពុជា សមត្ថកិច្ចត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ ត្រូវអនុវត្តនូវវិធានការដូចតទៅ :

- បញ្ជូនទំនិញត្រឡប់ទៅប្រទេសដើមវិញ
- បង្វែរទិសដៅប្រើប្រាស់ទំនិញ
- ដឹកជញ្ជូន និងដាក់ទំនិញតាមកន្លែងដែលសមត្ថកិច្ចត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វបានកំណត់
- បង្ខាំងសត្វនៅស្ថានីយ៍ចត្តាឡីស័កសត្វទុកសម្រាប់សង្កេតតាមដាន ធ្វើរោគវិនិច្ឆ័យ ទុកព្យាបាល ចាក់ថ្នាំការពារ ឬធ្វើការរំងាប់មេរោគ
- បំផ្លាញចោល ។

ក្នុងករណីបំផ្លាញចោលឬបញ្ជូនទំនិញត្រឡប់ទៅប្រទេសដើមវិញ ត្រូវចាត់វិធានការតាមច្បាប់ជាធរមាន ។

ក្នុងករណីទុកព្យាបាលចាក់ថ្នាំការពារ ធ្វើការរំងាប់មេរោគ ឃាត់ទុក ឬបំផ្លាញចោលម្ចាស់ទំនិញឬតំណាង ត្រូវធានាទាំងស្រុងលើការថែរក្សា ការចំណាយផ្សេងៗ និងសេវាកម្ម ។

ស

## ជំពូកទី ៥
## ការត្រួតពិនិត្យអនាម័យសត្វ
## និងផលិតផលមានដើមកំណើតពីសត្វនាំចេញ

**មាត្រា ២១._**

ទំនិញដែលជាកម្មវត្ថុនៃការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វនាំចេញទៅក្រៅប្រទេស ត្រូវឆ្លងកាត់ការត្រួតពិនិត្យតាមដានគ្រប់លក្ខណបច្ចេកទេសអនាម័យរបស់បសុពេទ្យ ដូចមានចែងក្នុងមាត្រា ១៥ នៃអនុក្រឹត្យនេះ ។

**មាត្រា ២២._**

ការនាំទំនិញដែលជាកម្មវត្ថុនៃការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វចេញពីព្រះរាជាណាចក្រកម្ពុជា ត្រូវធ្វើការត្រួតពិនិត្យអនាម័យនៅកន្លែងដើម ឬនៅក្នុងស្ថានីយ៍ចត្តាឡីស័កសត្វ ។

ទំនិញដែលជាកម្មវត្ថុនៃការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វត្រូវសមស្របតាមលក្ខខណ្ឌ ដូចមានចែងក្នុងបទប្បញ្ញត្តិកិច្ចសន្យាពាណិជ្ជកម្ម កិច្ចព្រមព្រៀង អនុសញ្ញា និងបណ្តាលក្ខខណ្ឌដទៃទៀតរបស់ប្រទេសនាំចូល ។

**មាត្រា ២៣._**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលដឹកជញ្ជូនសត្វ ឬផលិតផលមានដើមកំណើតពីសត្វចេញទៅក្រៅប្រទេស ត្រូវអនុវត្តតាមបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា៩ មាត្រា១០ និងមាត្រា១១នៃអនុក្រឹត្យនេះ ។

**មាត្រា ២៤._**

ទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វដែលដឹកជញ្ជូនចេញក្រៅប្រទេស បើពិនិត្យឃើញថាមានរោគសញ្ញាដែលអាចបង្កជំងឺឆ្លងរាតត្បាតបានសមត្ថកិច្ចត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ នៅតាមទីស្នាក់ការត្រួតពិនិត្យ ត្រូវផ្អាកការឆ្លងកាត់ជាបណ្តោះអាសន្ន ដើម្បីអនុវត្តវិធានបសុពេទ្យ ។ ការផ្អាកជាបណ្តោះអាសន្ននេះ សមត្ថកិច្ច

ﾚ

ត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ ត្រូវរាយការណ៍ជាបន្ទាន់ទៅនាយកដ្ឋានផលិតកម្ម និងបសុពេទ្យាបាល ដើម្បីសុំវិធានការពីរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

## ជំពូកទី ៦

## ការត្រួតពិនិត្យអនាម័យសត្វ

## និងផលិតផលមានដើមកំណើតពីសត្វឆ្លងកាត់

**មាត្រា ២៥.-**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលដឹកសត្វ ឬផលិតផលមានដើមកំណើតពីសត្វឆ្លងកាត់លើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវគោរពតាមលក្ខខណ្ឌដូចតទៅ :

- ត្រូវមានវិញ្ញាបនបត្រអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ ដែលចេញដោយប្រទេសនាំចេញ
- ត្រូវអនុវត្តតាមមាត្រា ៩ នៃអនុក្រឹត្យនេះ លើកលែងតែវាក្យខណ្ឌទី៦
- ត្រូវធានាមិនបើកសៀលសុវត្ថិភាព
- រាល់មធ្យោបាយដឹកជញ្ជូនទាំងអស់ ពុំត្រូវមានការចម្លងនូវមេរោគបង្កជំងឺ ឬជំងឺឆ្លងរាតត្បាតដែលអាចរាលដាលបាននៅតាមផ្លូវដឹកជញ្ជូនឆ្លងកាត់នេះ ។

**មាត្រា ២៦.-**

បែបបទនៃការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ លើទំនិញដឹកជញ្ជូនឆ្លងកាត់ ត្រូវកំណត់ដូចខាងក្រោម :

- ម្ចាស់ទំនិញត្រូវជូនដំណឹងដល់សមត្ថកិច្ចត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វនៅទីស្នាក់ការ មុនពេលទំនិញទាំងនោះមកដល់ច្រកទ្វារព្រំដែនចូល និងច្រកទ្វារព្រំដែនចេញ
- សមត្ថកិច្ចត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ ត្រូវធ្វើការត្រួតពិនិត្យមធ្យោបាយដឹកជញ្ជូនផ្ទៃខាងក្រៅ នៃបន្ទុកផលិតផលមានដើមកំណើតពីសត្វសុខភាពសត្វ និង

វិញ្ញាបនបត្រអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វរបស់ប្រទេសនាំចេញ ហើយត្រូវសម្រួលឱ្យការដឹកជញ្ជូនបន្តបានឆាប់រហ័ស ។

**មាត្រា ២៧.-**

ទំនិញដែលជាកម្មវត្ថុនៃការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ មិនស្របតាមលក្ខខណ្ឌដែលមានចែងក្នុងបទប្បញ្ញត្តិកិច្ចសន្យាពាណិជ្ជកម្ម កិច្ចព្រមព្រៀង អនុសញ្ញា និងបណ្ដាឯកសារ ដទៃទៀតស្តីពីអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ ត្រូវអនុវត្តតាមលក្ខខណ្ឌ ដូចមានចែងក្នុង មាត្រា ២០ នៃអនុក្រឹត្យនេះ ។

ក្នុងករណីគ្រោះថ្នាក់ដោយចៃដន្យក្នុងពេលដឹកជញ្ជូនបណ្ដាលឱ្យមានការបាក់បែក ឬរបើកសម្ភារៈវេចខ្ចប់ទំនិញ ឬគ្រោះថ្នាក់ដល់សត្វ ម្ចាស់ទំនិញត្រូវរាយការណ៍ជាបន្ទាន់ដល់សមត្ថកិច្ចត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ អាជ្ញាធរមានសមត្ថកិច្ច ដែលនៅជិតបំផុត ។ សមត្ថកិច្ចត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ ត្រូវពិនិត្យ និងអនុវត្តវិធានបសុពេទ្យជាបន្ទាន់រួចផ្តល់វិញ្ញាបនបត្រត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វសម្រាប់បន្តការនាំចេញ ។

## ជំពូកទី ៧
## សមត្ថកិច្ចរបស់មន្ត្រីត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ

**មាត្រា ២៨.-**

មន្ត្រីត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វមានសមត្ថកិច្ចដូចតទៅ :

- ត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ និងអនុវត្តវិធានបសុពេទ្យលើមធ្យោបាយដឹកជញ្ជូន និងទំនិញដែលជាកម្មវត្ថុនៃការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ នៅតាមឃ្លាំងស្តុក រោងចក្រ សហគ្រាស កសិដ្ឋាន ស្ថានីយ៍ចត្តាឡីស័កសត្វ និងទីស្នាក់ការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ ដោយសហ

ការជាមួយសមត្ថកិច្ចពាក់ព័ន្ធក្នុងករណីចាំបាច់

- ធ្វើកំណត់ហេតុនៃបទល្មើស និងចងក្រងសំណុំរឿងបញ្ជូនទៅតុលាការ

ម្ចាស់កម្មសិទ្ធិ ឬអ្នកកាន់កាប់អចលនទ្រព្យខាងលើ ត្រូវអនុញ្ញាតឱ្យមន្ត្រីត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វចូលពិនិត្យ និងត្រូវជួយសហការផ្តល់ព័ត៌មានដល់មន្ត្រីត្រួត-ពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ ។

**មាត្រា ២៩.-**

អាជ្ញាធរមានសមត្ថកិច្ចត្រូវជួយផ្តល់អន្តរាគមន៍ ក្នុងកិច្ចប្រតិបត្តិការត្រួតពិនិត្យអនាម័យសត្វនិងផលិតផលមានដើមកំណើតពីសត្វ ក្នុងករណីមានការស្នើសុំពីមន្ត្រីត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ ។

## ជំពូកទី ៨
## ទោសប្បញ្ញត្តិ

**មាត្រា ៣០.-**

ជនណាប្រព្រឹត្តល្មើសនឹងមាត្រា ៩ វាក្យខណ្ឌទី១ ២ ៣ ៤ ៥ ៧ ក្នុងអនុក្រឹត្យនេះ នឹងត្រូវទទួលពិន័យ ដោយយោងទៅតាមមាត្រា ៦២ ជំពូកទី ៧ នៃច្បាប់ស្តីពីការគ្រប់គ្រងគុណភាពសុវត្ថិភាព លើផលិតផលទំនិញ និងសេវា ។

**មាត្រា ៣១.-**

ជនណាប្រព្រឹត្តល្មើសនឹងមាត្រា ១៤ មាត្រា១៨ កថាខណ្ឌទី១ ក្នុងអនុក្រឹត្យនេះ នឹងត្រូវទទួលពិន័យ និងផ្តន្ទាទោស ដោយយោងទៅតាមមាត្រា ៦៣ ជំពូកទី ៧ នៃច្បាប់ស្តីពីការគ្រប់គ្រងគុណភាពសុវត្ថិភាព លើផលិតផលទំនិញ និងសេវា ។

**មាត្រា ៣២.-**

បើជនល្មើសណាមិនព្រមបង់ប្រាក់ពិន័យត្រូវបញ្ជូនសំណុំរឿងទៅតុលាការ ។

រង្វាន់លើកទឹកចិត្តដល់អ្នកមានស្នាដៃ និងចំណាយផ្សេងៗក្នុងការបំពេញបេសកកម្មនេះត្រូវកំណត់

ﾑ

ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ជំពូកទី ៩

## អវសានប្បញ្ញត្តិ

**មាត្រា ៣៣.-**

អនុក្រឹត្យលេខ ១៤ អនក្រ. ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ១៩៨៨ ស្ដីពីការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ និងបទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- គ្រប់សាលាខេត្ត ក្រុង
- ដូចមាត្រា ៣៤
- ឯកសារ-កាលប្បវត្តិ